**បណ្ដាញសហគមន៍ ព្រៃឡង់**
**ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា**

PREY LANG
IT'S OUR FOREST TOO

# សេចក្ដីថ្លែងការណ៍
# ការកាប់ឈើក្នុងតំបន់ព្រៃឡង់មានការកើនឡើងយ៉ាងខ្លាំងក្លា

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្ដាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និង កំពង់ធំ ដែលកំពុងធ្វើការងារស្ម័គ្រចិត្តការពារ និងឃ្លាំមើលស្ថានភាពព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់យ៉ាងយកចិត្តទុកដាក់ **មានកង្វល់យ៉ាងខ្លាំងក្លា ចំពោះការកាប់បំផ្លាញនិងដឹកជញ្ជូនឈើអាណាធិបតេយ្យ និងសកម្មភាពល្មើសច្បាប់ជាច្រើនផ្សេងទៀតដែលកំពុងកើតមានឡើងនៅក្នុងតំបន់ព្រៃឡង់។**

យើងខ្ញុំទាំងអស់គ្នាបានសង្កេតឃើញសកម្មភាពល្មើសច្បាប់អនាធិបតេយ្យនៅជុំវិញតំបន់ព្រៃឡង់ មានដូចជា៖ **១. ការអនុញ្ញាតឲ្យមានការដឹកជញ្ជូនឈើជាច្រើនគោយន្តក្នុងមួយថ្ងៃៗ និងឧបករណ៍សម្រួលដល់ការកាប់ឈើ កាត់មុខស្នាក់ការយាមល្បាតរបស់មន្ត្រីឧទ្យានុរក្សនីមួយៗ។ ២. ការកាប់រានដីព្រៃនៅក្នុង និងព្រៃតំបន់ទ្រនាប់ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ ដោយអ្នកមានអំណាច និងប្រជាពលរដ្ឋអ្នកចំណូលថ្មី។ ៣. ការដំឡើងរោងម៉ាស៊ីនអារ កែច្នៃឈើ និងផលិតក្ដាបន្ទះ ដោយក្រុមហ៊ុន ស៊ីង បាយអូថេក (ខេមបូឌា) ខូ អិលធីឌី នៅចំនុចភូមិសាស្ត្រភូមិកំពង់ដំរី ឃុំបឹងចារ ខណៈក្រុមហ៊ុនបានសម្រេចផ្អាក់សកម្មភាពរបស់ខ្លួនទាំងអស់ រហូតមានការវាយតម្លៃផលប៉ះពាល់បរិស្ថាននៅក្នុងជំនួបអន្តរក្រសួងនៅឆ្នាំ២០១៨។ ៤. ការចេញលិខិតអនុញ្ញាតដោយ មន្ត្រីអាជ្ញាធរមូលដ្ឋាន ឱ្យប្រជាជនកាប់ឈើនៅក្នុងតំបន់ព្រៃឡង់ក្រោមហេតុផលសាងសង់ផ្ទះ ខណៈព្រៃការពារមិនត្រូវបានអនុញ្ញាតឱ្យមានការកាប់ដកហូតគ្រប់រូបភាព។ ៥. ការប្រើប្រាស់អាវុធកែច្នៃនៅជុំវិញតំបន់ព្រៃឡង់ ក្នុងគោលបំណងបរបាញ់សត្វព្រៃ។ ៦. ការធ្វើអាជីវកម្មរ៉ែមាសដោយក្រុមហ៊ុន និងជនអាណាធិបតេយ្យ។**

**សកម្មភាពល្មើសច្បាប់អាណាធិបតេយ្យទាំងប្រាំមួយធំៗខាងលើនេះ យើងខ្ញុំទាំងអស់គ្នាបានកត់សម្គាល់ឃើញថា គ្មានវិធានការណាមួយទប់ស្កាត់គួរឱ្យកត់សម្គាល់ឡើយ។**

នៅក្នុងរបាយការណ៍សកម្មភាពឆ្នាំ២០១៨ ដែលយើងខ្ញុំបានកត់ត្រាទុកបន្ទាប់ពីការចុះល្បាតដោយស្ម័គ្រចិត្តក្រោមកិច្ចសហការរវាងមន្ត្រីឧទ្យានុរក្ស និងអាជ្ញាធរមូលដ្ឋាន បានបង្ហាញពីការរកឃើញ និងដកហូតប្រគល់ជូនមន្ត្រីជំនាញដូចជា៖ **ម៉ាស៊ីនរណារយន្តចំនួន ៩៨គ្រឿង (បើធៀបនឹងឆ្នាំ២០១៧ ដកហូតមានតែ ៥៦គ្រឿង) កាំភ្លើងកែឆ្នៃចំនួន ២១ដើម (បើធៀបនឹងឆ្នាំ២០១៧ ដកហូតបានតែ ១១ដើម) អន្ទាក់ដាក់សត្វព្រៃ ៥៨១អន្ទាក់ (បើធៀបនឹងឆ្នាំ២០១៧ ដកហូតបានតែ ៥០អន្ទាក់) ធ្វើកិច្ចសន្យាជាមួយម្ចាស់គោយន្តចំនួន ១៣គ្រឿង ឧបករណ៍ឆក់ត្រីចំនួន ២គ្រឿង ឈើអារជ្រៀករួចចំនួន៥៩.៤៥ ម៉ែត្រគូប ឈើកាត់រម្លំរួចចំនួន ៧៤ដើម និងគល់ឈើថ្មីចំនួន ៧១៩គល់។**

យើងខ្ញុំទាំងអស់គ្នា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ មេត្តា៖

**១. ស្នើសុំអោយរាជរដ្ឋាភិបាលតាមដាន និងត្រួតពិនិត្យ មន្ត្រីឧទ្យានុរក្សមួយចំនួន ដែលអសកម្ម ហើយនិងមិនបានបំពេញតួនាទីរបស់ខ្លួន។**

២. បញ្ឈប់ការអនុញ្ញាតឲ្យមានការដឹកជញ្ជូនឈើ ម៉ាស៊ីនរណាយន្ត និងសំភារៈផ្សេងទៀតសំរាប់បម្រើអោយការកាប់បំផ្លាញព្រៃឈើកាត់មុខប៉ុស្តិ៍យាមរបស់មន្ត្រីឧទ្យានុរក្សនីមួយៗ។

៣. សូមអាជ្ញាធរបញ្ឈប់ការផ្តល់លិខិតអនុញ្ញាត ឱ្យប្រជាជនចូលកាប់ឈើក្នុងតំបន់ការពារ។

៤. ស្នើសុំឲ្យក្រសួងបរិស្ថានរៀបចំផែនការយុទ្ធសាស្ត្រជាក់លាក់ក្នុងការប្រយុទ្ធប្រឆាំងការកាប់បំផ្លាញព្រៃឈើ និងការកាប់រានដីព្រៃសំរាប់កសិកម្មថ្មីៗ កាំភ្លើងកែឆ្នៃ ការបរបាញ់ នឹងសំភារៈសំរាប់បំរើអោយការប្រព្រឹត្តិបទល្មើសផ្សេងទៀត។

៥. ស្នើសុំអោយមានការធ្វើបច្ចុប្បន្នភាពយន្តការគ្រប់គ្រងព្រៃឈើ ព្រោះសព្វថ្ងៃការអនុវត្តយន្តការគ្រប់គ្រងព្រៃឈើនៅមានកំរិត នឹងហាក់ដូចជាមិនមានសុឆន្ទៈក្នុងការការពារព្រៃឈើ។

៦. សូមឱ្យរាជរដ្ឋាភិបាល ចាត់វិធានការដកហូតម៉ាស៊ីនរណាយន្តទាំងអស់ ចេញពីភូមិឃុំស្រុក ខេត្ត និងទីតាំងធ្វើអាជីវកម្ម នៅជុំវិញព្រៃឡង់ទាំងបួនខេត្ត និងបញ្ឈប់ការនាំចូលបន្តទៀត។

៧. រាជរដ្ឋាភិបាលត្រូវតែអនុវត្តន៍បទបញ្ញត្ត នឹងច្បាប់នានាក្នុងកិច្ចការការពារព្រៃឈើ។

៨. រាជរដ្ឋាភិបាលត្រូវតែធ្វើការវាយតំលៃ និងដាក់ទោសទាន់ចំពោះមន្ត្រីណា ដែលមិនបានបំពេញកាតព្វកិច្ច ឬមានការពាក់ពន្ធ័នឹងសកម្មភាពខុសច្បាប់។

៩. រាជរដ្ឋាភិបាលត្រូវគ្រប់គ្រង នឹងដកហូតរាល់អាវុធកែច្នៃដែលកំពុងប្រើប្រាស់ក្នុងភូមិស្រុកជុំវិញតំបន់ព្រៃឡង់។

១០. រាជរដ្ឋាភិបាលត្រូវបញ្ឈាប់រាល់សកម្មភាពដីសម្បទានសេដ្ឋកិច្ច រោងម៉ាស៊ីនអារឈើ រោងសិប្បកម្មការរុករករ៉ែ និងឡឥដ្ឋ ជុំវិញព្រៃឡង់។

១១. អំពាវនាវ និងលើកទឹកចិត្តដល់ប្រជាជនកម្ពុជា និងសាកលលោក សូមចូលរួមយ៉ាងសកម្ម និងធ្វើការទាំងអស់គ្នាទោះដោយផ្ទាល់ ឬប្រយោលដើម្បីបុព្វហេតុការពារធនធានធម្មជាតិ។

១២. សូមអោយតួអង្គអន្តរជាតិសំខាន់ៗ ធ្វើការចាប់អារម្មណ៍វិភាជ៏ធនធានទៅដល់បណ្តាប្រទេសដែលរងផលប៉ះពាល់ការកាប់បំផ្លាញព្រៃឈើ និងធនធានធម្មជាតិ។

១៣. បញ្ឈប់រាល់អាជីវកម្មឈើហ៊ុប និងឈើគ្រឿងផ្សេងក្នុងតំបន់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទដូចខាងក្រោម៖

១. លោក ឯក សុវណ្ណា ០៩៧ ៦៤៤ ៩៩៩៨/០៩៨ ៨៤៥ ៩៧៩

២. លោក ស្រី ថី ០៩៩ ៧២២ ១៨៧

៣. លោក ម៉ិញ នី ០៩៦ ៣០០ ២៧៦២

៤. កញ្ញា ឈាង លី ០៩៦ ៦៦៨ ០៦៧៣

យើងរួមគ្នាការពារព្រៃឡង់ "ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា!"

ធ្វើនៅថ្ងៃចន្ទ ១៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩